**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសាធារណការ និង ដឹកជញ្ជូន

**ក្រសួងអភិវឌ្ឍន៍ជនបទ**

លេខ: [illegible] បក. [illegible]

# ប្រកាសអន្តរក្រសួង
# ស្តីពី
## ការកំរិតកំណត់ទំងន់ អតិបរមា នៃរថយន្តដឹកជញ្ជូន ផ្លូវគោក ដែលបើកបរលើបណ្តាញផ្លូវខេត្ត និង ផ្លូវជនបទ នៃព្រះរាជាណាចក្រកម្ពុជា

## រដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន
## និង រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ។
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ខែមករាឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និង ដឹកជញ្ជូន ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ។
- បានឃើញព្រះរាជក្រឹត្យលេខ ៦៨ក្រ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ ១៩៩១ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ចរាចរផ្លូវគោក ។
- បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ-បក ចុះថ្ងៃទី០៣ ខែមិនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសាធារណការ និង ដឹកជញ្ជូន ។
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ / បក / ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួង និង រដ្ឋលេខាធិការដ្ឋាន។

- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ / បក ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ។

- បានឃើញអនុក្រឹត្យលេខ៩១ អនក្រ/បក ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ២០០១ ស្តីពីការធ្វើវិសោធនកម្មលើអនុក្រឹត្យលេខ៧៨ អនក្រ/បក ចុះថ្ងៃទី០១ ខែ ធ្នូ ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ។

- ដោយបានការឯកភាពពីគណៈរដ្ឋមន្ត្រី នាសម័យប្រជុំពេញអង្គថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ១៩៩៩។

- យោងតាមអនុសាសន៍របស់សម្តេចនាយករដ្ឋមន្ត្រីចុះថ្ងៃទី ២៩ ខែ មិនា ឆ្នាំ ២០០៤ ក្នុងឱកាសសម្ពោធបើកការដ្ឋានសាងសង់ស្ពានដើមស្តៅ ស្រុកកោះសូទិន ខេត្តកំពង់ចាម ។

## **សំរេច**

**ប្រការ១ :**

ប្រកាសនេះ មានគោលបំណងកំណត់ការគ្រប់គ្រងទម្ងន់រថយន្តដឹកជញ្ជូនទំនិញតាមបណ្តាញផ្លូវខេត្ត និង ផ្លូវជនបទទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជា សំដៅធានាភាពស្ថិតស្ថេរ របស់ផ្លូវថ្នល់ឱ្យបានយូរអង្វែងស្របតាមបច្ចេកទេស នៃការស្ថាបនាផ្លូវថ្នល់ ។

**ប្រការ២ :**

**និយមន័យ**

ក. **ត្រូវបានហៅថា :**

- រថយន្តដឹកជញ្ជូន : សំដៅរថយន្តដែលមានម៉ាស៊ីនភ្ជាប់ជាមួយភ្លៅរថយន្ត គឺអ័ក្សរបស់រថយន្ត ដែលភ្ជាប់ដោយកង់រថយន្តខាងឆ្វេង និង ខាងស្តាំ ។ កង់នោះអាចជាកង់សាមញ្ញ ឬ កង់ភ្លោះ ។
- ភ្លៅទោល : គឺជាភ្លៅរថយន្ត ដែលមានចំងាយយ៉ាងតិច ១,៨០ម៉ែត្រ ពីភ្លៅមួយទៀត ។
- ភ្លៅឌុប : សំដៅភ្លៅរថយន្តពីរ នៅចំងាយពីគ្នាតិចជាង ១,៨០ម៉ែត្រ និង ឆ្ងាយជាង ១,៣០ម៉ែត្រ

ខ. **ផ្លូវខេត្ត :**

១. ផ្លូវខេត្តជាផ្លូវដែលចេញពីខេត្ត ឆ្ពោះទៅកាន់ទីរួមស្រុក

២. ផ្លូវបំបែកចេញពីផ្លូវជាតិ ឆ្ពោះទៅទីរួមខេត្ត

៣. ផ្លូវបំបែកពីផ្លូវខេត្តឆ្ពោះទៅស្រុកក្នុងករណីចំនួនចរាចរមធ្យមប្រចាំថ្ងៃ (ADT) លើសពី ៥០ ។

៤. ផ្លូវបែកចេញពីផ្លូវខេត្តឆ្ពោះទៅផ្លូវខេត្ត។

៥. ផ្លូវជនបទក្នុងករណីចំនួនចរាចររថយន្តមធ្យមប្រចាំថ្ងៃ (ADT) ធំជាង ៥០។

៦. ផ្លូវផ្សេងៗទៀតតាមការកំណត់របស់ក្រសួងសាធារណការ និង ដឹកជញ្ជូន ។

- **ប្រភេទលេខផ្លូវខេត្ត :**

ផ្លូវខេត្តមានលេខ៣ខ្ទង់ លេខ៤ខ្ទង់ និង លេខ២ខ្ទង់និងអក្សរតាងឈ្មោះខេត្តនៅកណ្តាល

គ. **ផ្លូវជនបទ :**

១ - ផ្លូវដែលចេញពីផ្លូវជាតិឆ្ពោះទៅឃុំ - ភូមិ

២ - ផ្លូវដែលចេញពីផ្លូវខេត្តឆ្ពោះទៅ ឃុំ - ភូមិ

៣- ផ្លូវដែលចេញពីទីរួមស្រុក ទៅ ទីរួមស្រុក

៤ - ផ្លូវចេញពីទីរួមស្រុកទៅឃុំ

៥ - ផ្លូវចេញពីឃុំ ទៅ ឃុំ

៦ - ផ្លូវចេញពីឃុំ ទៅ ភូមិ

៧ - ផ្លូវបែកពីភូមិ ទៅ ភូមិ

៨ - ផ្លូវជនបទ ទៅ ផ្លូវផ្សេងទៀត

- ក្រុមបណ្តាញផ្លូវខេត្ត : តាមប្រកាសរបស់ក្រសួងសាធារណការ និង ដឹកជញ្ជូន ។
( ដូចមានចែងក្នុងឧបសម្ព័ន្ធ ១ )
- ក្រុមបណ្តាញផ្លូវជនបទ : តាមប្រកាសរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ។

**ប្រការ៣ :**

ទំងន់រថយន្តដឹកជញ្ជូន ដែលធ្វើចរាចរតាមក្រុមបណ្តាញផ្លូវខេត្ត ដូចបានចែងខាងលើត្រូវបានកំណត់អតិបរមាដូចតទៅ :

១-ចំពោះរថយន្តដឹកជញ្ជូនដែលមានភ្លៅ២គីរិតទំងន់ជាអតិបរមាអនុញ្ញាតិគឺ ១៦តោន ។

២-ចំពោះរថយន្តដឹកជញ្ជូនដែលមានភ្លៅ៣គីរិតទំងន់ជាអតិបរមាអនុញ្ញាតិគឺ ២០តោន ។

(ដូចបានចែងក្នុងតារាងឧបសម្ព័ន្ធទី២) ។

**ប្រការ៤ :**

ទំងន់រថយន្តដឹកជញ្ជូន ដែលធ្វើចរាចរតាមក្រុមបណ្តាញផ្លូវជនបទ ដូចបានចែងខាងលើ ត្រូវបានកំណត់ជាអតិបរមាដូចតទៅ :

- ចំពោះរថយន្តយន្តដឹកជញ្ជូនដែលមានភ្លៅ ២ គីរិតទំងន់ជាអតិបរមាអនុញ្ញាតិ គឺ៦តោន ។

**ប្រការ៥ :**

- **ផ្លូវខេត្ត :**

មិនអនុញ្ញាតិអោយរថយន្តសណ្តោង រថយន្តដឹកកុងតឺន័រ រថយន្តកែច្នៃធ្វើចរាចរ ។ ក្នុងករណីមានការដឹកជញ្ជូនពិសេស ដែលមានទំងន់លើសពីគីរិតទំងន់ដែលបានចែងក្នុងប្រកាសនេះ ហើយ ដែលមានលក្ខណៈចាំបាច់ និងប្រព្រឹត្តិឡើងម្តងម្កាល ម្ចាស់រថយន្តត្រូវធ្វើពាក្យសុំអនុញ្ញាតិមក នាយកដ្ឋានផ្លូវថ្នល់ មន្ទីរសាធារណការ និង

ដឹកជញ្ជូន (ភ្ជាប់ជាមួយតារាងប្រភេទរថយន្តដឹកជញ្ជូន) ដើម្បីពិនិត្យ និងសំរេច តែត្រូវធ្វើការជូសជុលថែទាំផ្លូវថ្នល់-ស្ពានប្រសិនបើមានការខូចខាតពេលដឹកជញ្ជូនបានបញ្ចប់។

**- ផ្លូវជនបទ :**

មិនអនុញ្ញាតិអោយ រថយន្តសណ្តោង រថយន្តដឹកកុងតឺន័រ រថយន្តកែច្នៃ និង រថយន្តមានភ្លៅបីធ្វើចរាចរ។ ក្នុងករណីមានការដឹកជញ្ជូនពិសេស ដែលមានទំងន់លើសពីកំរិតទំងន់ដែលបានចែងក្នុងប្រកាសនេះ ហើយដែលមានលក្ខណៈចាំបាច់ និងប្រព្រឹត្តិឡើងម្តងម្កាលម្ចាស់រថយន្តត្រូវធ្វើពាក្យសុំអនុញ្ញាតិមក នាយកដ្ឋានផ្លូវលំ មន្ទីរអភិវឌ្ឍន៍ជនបទ (ភ្ជាប់ជាមួយតារាងប្រភេទរថយន្ត ដឹកជញ្ជូន) ដើម្បីពិនិត្យ និងសំរេច តែត្រូវធ្វើការជូសជុលថែទាំផ្លូវថ្នល់-ស្ពានប្រសិនបើមានការខូចខាតពេលដឹកជញ្ជូន បានបញ្ចប់។

**<u>ប្រការ៦</u> :**

-កំរិតកំណត់ទំងន់អនុញ្ញាតិឆ្លងកាត់ស្ពានដែលសរសេរលើផ្លាកសញ្ញាចរាចរ គឺជាទំងន់អនុញ្ញាតិនៃរថយន្តដឹកជញ្ជូន។

-លើកំណាត់ផ្លូវទាំងឡាយណាដែលមានស្ពានទ្រុឌទ្រោម ហើយរដ្ឋពុំទាន់មានលទ្ធភាពស្តារឡើងវិញនោះមន្ទីរសាធារណការ និង ដឹកជញ្ជូន និង មន្ទីរអភិវឌ្ឍន៍ជនបទខេត្ត-ក្រុង ត្រូវធ្វើលិខិតជូនដំណឹង និង ផ្សព្វផ្សាយជាសាធារណៈជូនដល់បុគ្គលក្រុមហ៊ុនដឹកជញ្ជូន អាជ្ញាធរមូលដ្ឋាន និង ដាក់ផ្លាកសញ្ញាបង្ហាញទីតាំងស្ពានទ្រុឌទ្រោមនោះនៅដើមផ្លូវចូលដែលជិតជាងគេបំផុតនិងនៅក្បាលស្ពានសងខាង។

**<u>ប្រការ៧</u> :**

- ចំពោះស្ពានតាមបណ្តោយផ្លូវខេត្ត និង ផ្លូវជនបទទាំងអស់ មន្ទីរសាធារណការ និង ដឹកជញ្ជូន មន្ទីរអភិវឌ្ឍន៍ជនបទត្រូវដាក់របារក្នុងករណីចាំបាច់ ដាក់បង្គោលសុវត្ថិភាព (ចន្លោះ 2.30m) ចំពោះផ្លូវជនបទ និងផ្លាកសញ្ញាកំរិតទំងន់ដោយឆ្លងយោបល់ពីនាយកដ្ឋានផ្លូវថ្នល់ នឹង នាយកដ្ឋានផ្លូវលំ ធ្វើការផ្សព្វផ្សាយជាសាធារណៈ (របារកំរិតកំពស់ H = 3.50 m, សំរាប់ផ្លូវខេត្ត . H = 2.5 m សំរាប់ផ្លូវជនបទ) ។

**<u>ប្រការ៨</u> :**

ក្នុងករណីពិសេសដែលមានស្ពាន ឬ កំណាត់ផ្លូវកំពុងប៉ះពាល់ដោយទឹកជំនន់ ឬ ភ្លៀងធ្លាក់ជោគជាំនារដូវវស្សាដែលធ្វើអោយទ្រុងផ្លូវជ្រាយនោះការកំរិតកំណត់ដឹកជញ្ជូន ត្រូវបានកំណត់ដោយលិខិតជូនដំណឹងរបស់ក្រសួងសាធារណការនិងដឹកជញ្ជូននិងក្រសួងអភិវឌ្ឍន៍ជនបទគឺត្រូវគិតទំងន់ជាក់ស្តែងនៃទំងន់ដែលអនុញ្ញាតិនៅពេលនោះ ។

**<u>ប្រការ៩</u> :**

មន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន និង មន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ សហការជាមួយរដ្ឋអំណាចមូលដ្ឋាន មានសិទ្ធិគ្រប់គ្រាន់ក្នុងការ ទប់ស្កាត់ ដោយចាប់ផ្តើមពីការព្រមាន ពិន័យរហូតដល់ដកហូតប័ណ្ណបើកបរ

ក្នុងករណីចំពោះបុគ្គលណាដែលប្រើប្រាស់ផ្លូវថ្នល់ខុសពីខ្លឹមសារនៃប្រកាសនេះដែលបង្កអោយមានការខូចខាតផ្លូវស្ពាន បុគ្គលនោះត្រូវទទួលការផាកពិន័យដោយចេញសំណង។

**ប្រការ១០ :**

បុគ្គលណាដែលយកប្រកាសនេះទៅប្រើប្រាស់ខុសពីខ្លឹមសារ ឬ ក៏ទាញយកផលប្រយោជន៍ខុសពីផលប្រយោជន៍រដ្ឋធ្វើអោយមានភាពមិនទទួលខុសត្រូវលើភារកិច្ចរបស់ខ្លួន និង ត្រូវទទួលទោសចំពោះមុខច្បាប់។

**ប្រការ១១ :**

នាយខុទ្ទកាល័យ អគ្គនាយកសាធារណការ អគ្គនាយកបច្ចេកទេស អគ្គនាយករដ្ឋបាល នៃក្រសួងទាំងពីរ នាយកដ្ឋានផ្លូវថ្នល់ នាយកដ្ឋានផ្លូវលំ មន្ទីរសាធារណការ និង ដឹកជញ្ជូនខេត្ត-ក្រុង មន្ទីរអភិវឌ្ឍន៍ជនបទ ខេត្ត-ក្រុង និង អង្គភាពក្រោមឱវាទ នៃក្រសួងសាធារណការ និង ដឹកជញ្ជូន និង ក្រសួងអភិវឌ្ឍន៍ជនបទ ត្រូវទទួលបន្ទុកអនុវត្តនូវខ្លឹមសារ នៃប្រកាសនេះអោយមានប្រសិទ្ធភាព។

**ប្រការ១២ :**

ប្រកាសនេះចូលជាធរមានបញ្ញត្តិចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ , ថ្ងៃទី 23 ខែ 06 ឆ្នាំ ២០០៤
**រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ**

លី - ធុច

រាជធានីភ្នំពេញ , ថ្ងៃទី 23 ខែ 06 ឆ្នាំ ២០០៤
**រដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន**
**ស្តីទីប្រចាំការ**

**ត្រាំ អ៊ីវតឹក**

**កន្លែងទទួល**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ក្រសួង រដ្ឋលេខាធិការដ្ឋានជាស្ថាប័ន
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- សាលាខេត្ត-ក្រុង

  " ដើម្បីជ្រាប "
- មន្ទីរសាធារណការ និង ដឹកជញ្ជូនខេត្ត-ក្រុង
- មន្ទីរអភិវឌ្ឍន៍ជនបទខេត្ត-ក្រុង

  " ដើម្បីមុខការ "
- ដូចប្រការ ១១

  " ដើម្បីអនុវត្តន៍ "
- ឯកសារ-កាលប្បវត្ត

# ផ្លូវខេត្តដែលត្រូវរៀបចំជាថ្មី

## តំបន់ទី១ : ប៉ែកខាងត្បូងឈៀងខាងលិច(តំបន់ចន្លោះទន្លេមេគង្គខាងក្រោម និង ទន្លេសាប)

### កណ្ដាល_តាកែវ_កំពត_កំពង់ស្ពឺ_កំពង់ឆ្នាំង_ពោធិ៍សាត់_បាត់ដំបង_កោះកុង_ក្រុងកែប_ក្រុងប៉ៃលិន_ក្រុងព្រះសីហនុ_បន្ទាយមានជ័យ

| ល.រ | លេខផ្លូវ | | | ចំណុចចាប់ផ្ដើម | ចំណុចបញ្ចប់ | ប្រវែងផ្លូវសរុប(គ.ម) |
|---|---|---|---|---|---|---|
| | ចាស់ | ថ្មី | [illegible] | | | |
| ផ្លូវខេត្តក្នុងតំបន់១ | | | | | | |
| ១ | គ្មាន | ១១០ | កណ្ដាល | ច្បារអំពៅ ប.គ៩+៥០០ (ផ.ជ១) | ព្រែកជ្រៃ (ទល់ដែនវៀតណាម) | ៨៩.០០០ |
| ២ | គ្មាន | ១១២ | កណ្ដាល | ផ្លូវបោះអង្កាញ់ ប.គ១២+០៩០ (ផ.ជ១) | ទន្លេត្រើយខាងកើត (ផ.ខ១១០) | ៧.៨០០០ |
| ៣ | គ្មាន | ១១៤ | កណ្ដាល | ផ្លូវថៃយហ៊ួរ ប.គ១២+៥៦៥ (ផ.ជ១) | សាលារៀនបោះអង្កាញ់ (ផ.ខ១១២) | ៤.០៥០ |
| ៤ | គ្មាន | ១១៦ | កណ្ដាល | ផ្លូវវដ្ដនសរ ប.គ១៨+៩៥១ (ផ.ជ១) | ឃុំឈើទាល (ផ.ខ១១០) | ៦.០០០ |
| ៥ | គ្មាន | ១១៨ | កណ្ដាល | ស្រែអំពិល ប.គ២៤+៧០០ (ផ.ជ១) | ស្ពានព្រែកដូង (ផ.ខ១១០) | ៨.៣០០ |
| ៦ | ១០១ | ១១៨ក | កណ្ដាល | ប.គ៥៩+០៣៥ (ផ.ជ១) | ក្អមសំណរ (ទល់ដែនវៀតណាម) | ៤៣.២០០ |
| ៧ | គ្មាន | ១២០ | កណ្ដាល | ក្បាលថ្នល់ដីក្រហម ប.គ២០+៣០០ (ផ.ជ២) | បឹងជើងឯក | ៥.១០០ |
| ៨ | ១០៦ | ១២១ | តាកែវ | សំរោងយ៉ោង ប.គ៤១+៨០០ (ផ.ជ២) | បឹងជើងលូង | ២៣.២៤០ |
| ៩ | គ្មាន | ១២១ក | តាកែវ | ផ្សារចំបក់ ប.គ៤៤+៩០០ (ផ.ជ២) | ត្នោត-ចារ-ស្លារ-ព្រៃល្វា | ១៩.១០០ |
| ១០ | ១០៧ | ១២១ខ | តាកែវ | ផ្សារនាងខ្មៅ ប.គ៥០+៨៥០ (ផ.ជ២) | ព្រពាំងស្រង់ ប.គ៧+៣៥០ | ៥.៩៦០ |
| ១១ | ១០៤ | ១២២ | កណ្ដាល | ក្បាលថ្នល់ដីក្រហម ប.គ២០+៣០០ (ផ.ជ២) | កំពង់ទួល ប.គ២៤+៣៩៩ (ផ.ជ៣) | ៩.៦៣០ |
| ១២ | គ្មាន | ១២៣ | តាកែវ | ដើមធ្លក ប.គ៥២+៣០០ (ផ.ជ២) | ព្រពាំងស្រង់ ប.គ៧+៣៥០ | ៤.៤០០ |
| ១៣ | ១០៨ | ១២៣ក | តាកែវ | ថ្នល់ទទឹង ប.គ ៥៦ + ៥៨០ (ផ.ជ២) | កំពង់ចក | ២៦.០០០ |
| ១៤ | ១០៥ | ១២៤ | កណ្ដាល | សៀមរាប ប.គ២៥+៥៤០ (ផ.ជ២) | កំពង់កន្ទួត | ៦.៨០០ |
| ១៥ | ១០៩ | ១២៥ | តាកែវ | ផ្លូវបែកផ្សារតាគរ ប.គ ៧៥ +៤៦០ (ផ.ជ២) | តាកែវក្រុង | ០.៩៥០ |

| ល.រ | លេខផ្លូវ | | | ចំណុចចាប់ផ្តើម | ចំណុចបញ្ចប់ | ប្រវែងផ្លូវ |
|---|---|---|---|---|---|---|
| | ចាស់ | ថ្មី | ឈ្មោះខេត្ត | | | សរុប(គ.ម) |
| **ផ្លូវខេត្តក្នុងតំបន់១** | | | | | | |
| ១៦ | ១១០ | ១២៥ក | តាកែវ | តាកែវក្រុង ( ផ.ជ២) | ក្បាលពោធិ៍ | ១១.៨០០ |
| ១៧ | ១៧០ | ១២៥ខ | តាកែវ | ភូមិត្រពាំងលើក ប.គ៥០ + ៥៥០ ( ផ.ជ២) | កំពង់ទូក - កំពង់អំពិល | ១៧..៨០០ |
| ១៨ | ១០៦ | ១២៦ | តាកែវ | សំរោងយ៉ោង ប.គ៤១+៨០០ ( ផ.ជ២) | ក្រាំងខ្វាប.គ ៤៣+៨១០ ( ផ.ជ៣) | ១៥.០០០ |
| ១៩ | ១១៤ | ១២៦ក | តាកែវ | ផ្លូវបំបែកសន្ទុង ប.គ៩៧ +២៥០ ( ផ.ជ២) | តានី ប.គ១០២+០០ ( ផ.ជ៣១) | ១៦.៣៥០ |
| ២០ | ១១១ | ១២៧ | តាកែវ | ភូមិកំពង់ជ្រៃ ប.គ៩៩ + ៦៩១ ( ផ.ជ២) | សាលាស្រុកកោះអណ្តែត | ១៥.០០០ |
| ២១ | ១១២ | ១២៨ | តាកែវ | ទន្លាប់ ប.គ១១៧+១៥០ ( ផ.ជ២) | បាពល | ១៧.០០០ |
| ២២ | ១២៦ | ១៣០ | កំពង់ស្ពឺ | ដើមរកា ប.គ៣៦+៤៧០ ( ផ.ជ៣) | ប.គ៣+០០ ( ផ.ខ១៤៥) | ២៤.៥០០ |
| ២៣ | ១៦៩ | ១៣០ក | តាកែវ | អង្គតាសោម ប.គ៧៤+៨២០ ( ផ.ជ៣) | ផ្សារត្រពាំងអណ្តើក | ២១.០០០ |
| ២៤ | គ្មាន | ១៣១ | តាកែវ | ផ្សារក្រាំងកក់ ប.គ៩០+៦០០ ( ផ.ជ៣) | ស្មោងប.គ៩+២៨០ ( ផ.ជ៣១) | ១១.២០០ |
| ២៥ | គ្មាន | ១៣២ | តាកែវ | ផ្សារក្រាំងកក់ ប.គ៩០+៤០០ ( ផ.ជ៣) | វត្តត្រពាំងគោល ប.គ១២+៣០០ | ១៦.២០០ |
| ២៦ | គ្មាន | ១៣២ក | កំពត | វត្តស្ទឹងស្រុកឈូក ប.គ១០៦+០០ ( ផ.ជ៣) | ឃុំស្វាយអញ្ជិត ផ្លូវអង្គជួង | ២០.០០០ |
| ២៧ | គ្មាន | ១៣២ខ | កំពត | ផ្សារឈូក ប.គ១០៧+២៥០ ( ផ.ជ៣) | ស្រុកជុំគិរី ប.គ១១+០០ | ១១.០០០ |
| ២៨ | ១១៥ | ១៣៣ | កំពត | ស្រុកឈូក ប.គ១០២+៥០០ ( ផ.ជ៣) | ឃុំក្រាំងស្បូវ ស្រុកឈូក | ៦.៤៥០ |
| ២៩ | គ្មាន | ១៣៣ក | កំពត | ផ្សារឈូក ប.គ១០៧+២៥០ ( ផ.ជ៣) | ឃុំដំបូកខ្ពស់ ច្រកស្មៀម ប.គ១០៨+៥០០ ( ផ.ជ៣១) | ២០.០០០ |
| ៣០ | គ្មាន | ១៣៤ | កំពត | ឃុំល្អាង ស្រុកដងទង ប.គ១២៤+៥០០( ផ.ជ៣) | ប.គ៨៧+០០ ( ផ.ជ៤) | ៦៤.០០០ |
| ៣១ | ៦០ | ១៣៤ក | កំពត | ភូមិដូនស៊ីយ ស្រុកកំពត ប.គ១៣១+០០( ផ.ជ៣) | ឃុំត្រពាំងភ្លាំង ស្រុកដងទង់ប.គ១៤+០០ ( ផ្លូវកោះស្លា) | ២០.៧០០ |
| ៣២ | | ១៣៥ | កំពត | វិទ្យាល័យឈូក ប.គ១០៨+១០០ ( ផ.ជ៣) | ផ្សារស្រុកកំពង់ត្រាច ប.គ៣៥+៥០០ ( ផ.ជ៣៣) | ៣១.១០០ |
| ៣៣ | ១៧ | ១៣៦ | កំពត | កំពតក្រុង ប.គ១៤៨+៦០០ ( ផ.ជ៣) | ភូមិកំណប់ វត្តអង្គប.គ១៤១+១០០ ( ផ.ជ៣) | ១៥.៧០០ |

| ល.រ | លេខផ្លូវ | | | ចំណុចចាប់ផ្តើម | ចំណុចបញ្ចប់ | ប្រវែងផ្លូវ |
|---|---|---|---|---|---|---|
| | ចាស់ | ថ្មី | ខេត្តឆ្លងកាត់ | | | សរុប(គ.ម) |
| | | | | **ផ្លូវខេត្តក្នុងតំបន់១** | | |
| ៣៤ | ១១៨ | ១៣៧ | កំពត | អង់មាស ស្រុកដងទង់ ប.គ១១៩+០០( ផ.ជ៣) | សំរោងក្រោម ត្រាំសសរ ប.គ១១៣+០០ ( ផ.ជ៣១) | ២៨.០០០ |
| ៣៥ | ១២១ | ១៣៨ | កំពត | ភូមិ ថ្មី សង្កាត់៤ ស្រុកកំពង់បាយប.គ១៤៩+០០( ផ.ជ៣) | ទឹកឈូ ប.គ៨+៤០០ | ៨.៤០០ |
| ៣៦ | ១១៩ | ១៣៩ | កំពត | រោងចក្រស៊ីម៉ង់ត៍ ប.គ១៣៤+១០០( ផ.ជ៣) | សាលាស្រុកកំពតប.គ៥+៨២០( ផ.ជ៣៣) | ១២.២០០ |
| ៣៧ | ១៣១ | ១៤០ | កំពង់ស្ពឺ | ភ្នំស្រួច ប.គ៥៨+៨០០ ( ផ.ជ៤) | ភូមិកន្ទួត ប.គ៤៣+០០ | ៤៦.០០០ |
| ៣៨ | ១២៤ | ១៤១ | កំពង់ស្ពឺ | កំពង់ត្រាំ | ប.គ១២៧+០០ ( ផ.ជ៣) | ៨៥.២៧០ |
| ៣៩ | ១២៨ | ១៤៣ | កំពង់ស្ពឺ | ក្តីលា ប.គ៣៦+០០ ( ផ.ជ៤) | ប.គ៥០០+០០ | ៤.០០០ |
| ៤០ | ១២៧ | ១៤៥ | កំពង់ស្ពឺ | កំពង់ស្ពឺក្រុង | ព្រៃទទឹង ប.គ២៧+៩៣០( ផ.ជ៣) | ៣១.០០០ |
| ៤១ | ១២៥ | ១៤៧ | កំពង់ស្ពឺ | កំពង់ស្ពឺក្រុង | ត្រាំខ្នារប.គ៤៣+៨០០( ផ.ជ៣) | ៣៣.៩៨០ |
| ៤២ | គ្មាន | ១៤៩ | កំពង់ស្ពឺ | ត្រែងត្រយឹង ប.គ៨៧+៨៧៧ ( ផ.ជ៤) | ព្រំប្រទល់កំពត | ២២.០០០ |
| ៤៣ | ១៣៥ | ១៥០ | កណ្តាល | ប.គ៣៦+៩៨០ ( ផ.ជ៥) | ពាមលង្វែក | ១១.៤២៥ |
| ៤៤ | ១៣៧ | ១៥០ក | កំពង់ឆ្នាំង | លង្វែក ប.គ៤៥+០០ ( ផ.ជ៥) | ពាមលង្វែក ប.គ៦+០០ | ៦.៧៩៤ |
| ៤៥ | គ្មាន | ១៥០ខ | កំពង់ឆ្នាំង | សាលាលេខ៥ ប.គ៥៣+០០ | កំពង់ត្រឡាចក្រោម | ៨.០០០ |
| ៤៦ | ១៣៩ | ១៥០គ | កំពង់ឆ្នាំង | ក្បាលថ្នល់តាជេស ប.គ៦១+៦១៦ ( ផ.ជ៥) | ភូមិតាជេស | ៦.២៥០ |
| ៤៧ | ១៤១ | ១៥០ឃ | កំពង់ឆ្នាំង | ព្រៃខ្មែរ ប.គ៨១+៩០០( ផ.ជ៥) | គោកបន្ទាយ | ៣.៣០០ |
| ៤៨ | គ្មាន | ១៥១ | កណ្តាល | ព្រែកព្នៅ ប.គ១២+៩៥០ ( ផ.ជ៥) | ប.គ១៦+៣៥០ ( ផ.ជ៤២) | ១៨.៧០០ |
| ៤៩ | ១៣៤ | ១៥១ក | កណ្តាល | ប.គ៣៦+៩៨០ ( ផ.ជ៥) | ភ្នំឧត្តុង ( ព្រំប្រទល់ខេត្តកណ្តាល) | ៧ .៧០០ |
| ៥០ | ១៣៦ | ១៥១ខ | កំពង់ស្ពឺ | ឧត្តុងប.គ៣៩+៤៤៥ ( ផ.ជ៥) | ជ្រាវ ( កំពង់ស្ពឺ) | ៦១.០០០ |

| ល.រ | លេខផ្លូវ | | | ចំណុចចាប់ផ្តើម | ចំណុចបញ្ចប់ | ប្រវែងផ្លូវ |
|---|---|---|---|---|---|---|
| | ចាស់ | ថ្មី | ឆ្លងកាត់ខេត្ត | | | សរុប(គ.ម) |
| **ផ្លូវខេត្តក្នុងតំបន់១** | | | | | | |
| ៥១ | ១៣៧ | ១៥១ក | កំពង់ឆ្នាំង | លង្វែក ប.គ៤៥+០០ (ផ.ជ៥) | ត្បែងខ្ពស់ | ១០.៣០៧ |
| ៥២ | ១៤០ | ១៥២ | កំពង់ឆ្នាំង | ក្បាលថ្នល់សែប ប.គ៦៧+៥០០ (ផ.ជ៥) | ភូមិកំពង់ប្រាសាទ | ៤.៨០០ |
| ៥៣ | ១៤៣ | ១៥២ក | កំពង់ឆ្នាំង | ភូមិដំបូកកកោះ ប.គ៩៤+២២០ (ផ.ជ៥) | ទន្លេសាប | ៧ .០៨០ |
| ៥៤ | ១ | ១៥២ខ | ពោធិ៍សាត់ | អូរអាចកុក ប.គ១៦៥+០៦០ (ផ.ជ៥) | វត្តកំពង់ឡ | ១០.០០០ |
| ៥៥ | ២ | ១៥២គ | ពោធិ៍សាត់ | យ៉ាកាប់ ប.គ១៦៨+៤១០ (ផ.ជ៥) | ឃុំកំពង់ពោធិ៍ | ៨.០០០ |
| ៥៦ | ៤ | ១៥២ឃ | ពោធិ៍សាត់ | ក្រាំងតាសោម ប.គ១៧៣+៧៥០ (ផ.ជ៥) | ភូមិរលួស | ៩.០០០ |
| ៥៧ | ១៣៥ | ១៥៣ | កំពង់ស្ពឺ | ប.គ២៩+០២០ (ផ.ជ៥) | ពាមលង្វែក (ព្រំប្រទល់ខេត្តកណ្តាល) | ១១.៤៣០ |
| ៥៨ | ១៣៨ | ១៥៣ក | កំពង់ឆ្នាំង | សាលាលេខ៥ ប.គ៥៣+០០ | សាលាស្រុកតាំងខ្លោច | ៣៩.៧០១ |
| ៥៩ | ១៤១ | ១៥៣ខ | កំពង់ឆ្នាំង | ព្រៃខ្មែរ ប.គ៨១+៩០០(ផ.ជ៥) | ភូមិក្រាំងតាមុំ ប.គ១៧+៨៩០ (ផ.ជ៥៣) | ១៤.៤១០ |
| ៦០ | ១៤៥ | ១៥៣គ | កំពង់ឆ្នាំង | សាលក្មៅវ៉ាយ ប.គ៩៩+០០ (ផ.ជ៥) | ចំណោតក្រាំងស្គារ | ២៣.០០០ |
| ៦១ | ១៤៤ | ១៥៣ឃ | កំពង់ឆ្នាំង | ស្វាយជ្រុំ ប.គ១០០+៣០០ (ផ.ជ៥) | ប្រស្ទឹប | ១៩.០០០ |
| ៦២ | ៣ | ១៥៣ង | ពោធិ៍សាត់ | ថ្នាមមួម ប.គ១៧១+២៤០ (ផ.ជ៥) | ភូមិត្បែងជ្រុំ | ១០.០០០ |
| ៦៣ | ៥ | ១៥៣ច | ពោធិ៍សាត់ | តាកែវប.គ១៧៦+៣៩០ (ផ.ជ៥) | ភ៉ិទទឹងថ្ងៃ | ១០.១០០ |
| ៦៤ | ១៤៧ | ១៥៤ | ពោធិ៍សាត់ | ក្រុងពោធិ៍សាត់ ប.គ១៨៥+៨៧០ (ផ.ជ៥) | កញ្ជោ | ២៦.១២០ |
| ៦៥ | ៦ | ១៥៤ក | ពោធិ៍សាត់ | ត្នោតទ្រេត ប.គ១៨៩+៨០០ (ផ.ជ៥) | ភូមិបឹងកន្សែន | ១៤.០០០ |
| ៦៦ | ៨ | ១៥៤ខ | ពោធិ៍សាត់ | អណ្តូងក្រសាំង ប.គ១៩៨+២២០ (ផ.ជ៥) | ភូមិព្រាំពៃ | ១៤.៥០០ |
| ៦៧ | ១០ | ១៥៤គ | ពោធិ៍សាត់ | បាកាន ប.គ២០២+៦០០ (ផ.ជ៥) | ភូមិអូ | ១៨.០០០ |

| ល.រ | លេខផ្លូវ | | | ចំណុចចាប់ផ្តើម | ចំណុចបញ្ចប់ | ប្រវែងផ្លូវសរុប(គ.ម) |
|---|---|---|---|---|---|---|
| | ចាស់ | ថ្មី | ស្ថិតក្នុងខេត្ត | | | |
| ផ្លូវខេត្តក្នុងតំបន់១ | | | | | | |
| ៦៨ | ១៧៦ | ១៥៤យ | ពោធិ៍សាត់ | បឹងខ្នារ ប.គ២១០+៥០០ ( ផ.ជ៥) | កោះក្បាច់ ( តាមុំ) | ១២.០០០ |
| ៦៩ | ១១ | ១៥៤ង | ពោធិ៍សាត់ | រូងតាចេង ប.គ២១៦+២០០( ផ.ជ៥) | ស្តុកឃ្លោក | ២០.០០០ |
| ៧០ | ១៤៩ | ១៥៤ច | បាត់ដំបង | ស្ពានមោង ប.គ២៤៤+៥០០ ( ផ.ជ៥) | ដូនទ្រី | ១៣.៦០០ |
| ៧១ | ១៤៦ | ១៥៥ | ពោធិ៍សាត់ | ក្រុងពោធិ៍សាត់ ប.គ១៨៥+៣១០ ( ផ.ជ៥) | ស្រែអំបិល ( កោះកុង) | ១៦៣.០០០ |
| ៧២ | ១៤៨ | ១៥៥ក | ពោធិ៍សាត់ | ក្រុងពោធិ៍សាត់ ប.គ១៩១+២៥០ ( ផ.ជ៥) | ថ្មដា | ១៧៩.០០០ |
| ៧៣ | ៧ | ១៥៥ខ | ពោធិ៍សាត់ | ស្វាយប្រេះ ប.គ១៩៥+៤៧០ ( ផ.ជ៥) | ដប់បាត | ១១.៦០០ |
| ៧៤ | ៩ | ១៥៥គ | ពោធិ៍សាត់ | បាកាន ប.គ២០២+៣៦០ ( ផ.ជ៥) | ឃុំសំរោង | ៣០.០០០ |
| ៧៥ | ១៧៥ | ១៥៥ឃ | ពោធិ៍សាត់ | បឹងខ្នារប.គ២១០+៥០០ ( ផ.ជ៥) | ប៉ិលហាល | ៣២.០០០ |
| ៧៦ | គ្មាន | ១៥៥ង | បាត់ដំបង | វ៉ាចំហៀង ប.គ២២៨+០០ ( ផ.ជ៥) | ស្តុកប្រវឹក | ២៣.០០០ |
| ៧៧ | គ្មាន | ១៥៥ច | បាត់ដំបង | ស្ពានមោង ប.គ២៤៤+៥០០ ( ផ.ជ៥) | បាសាក់ | ២២.០០០ |
| ៧៨ | គ្មាន | ១៥៥ឆ | បាត់ដំបង | ផ្សារមោង ប.គ២៤៤+៨០០ ( ផ.ជ៥) | គាស់ក្រឡ | ១៨.០០០ |
| ៧៩ | ១៥៤ | ១៥៦ | បាត់ដំបង | ស្ពានថ្មថ្មី ប.គ២៩២+២០០ ( ផ.ជ៥) | នាយណំ-សាលាតាអន-ព្រែកអំបិល | ២០.៥០០ |
| ៨០ | ១៥៦ | ១៥៦ក | បាត់ដំបង | ស្ពានថ្មថ្មី ប.គ២៩២+៣០០ ( ផ.ជ៥) | ដូនទាវ-ព្រែកត្រប់ | ១៣.០០០ |
| ៨១ | ១៥០ | ១៥៧ | បាត់ដំបង | ព្រែកតូច ប.គ២៩៩+៨៤០ ( ផ.ជ៥) | គាស់ក្រឡ | ២៣.០០០ |
| ៨២ | គ្មាន | ១៥៧ក | បាត់ដំបង | កំពង់ព្រៀង ប.គ២៦៧+៦០០ ( ផ.ជ៥) | ស្វាយជាតិ | ១២.០០០ |
| ៨៣ | ១៥២ | ១៥៧ខ | បាត់ដំបង | វត្តកំណប់ ប.គ២៨០+០០ ( ផ.ជ៥) | អូរស្រឡៅ | ៩.៤០០ |
| ៨៤ | | ១៥៧គ | បាត់ដំបង | ប.គ២៨១+០១០ ( ផ.ជ៥) | បាណន់ | ១៩.២៧៦ |
| ៨៥ | ១៥០ | ១៥៨ | ប.ជ | មង្គលបុរី ប.គ៣៥០+៥០០ ( ផ.ជ៥) | ស្រះមោច ប.គ១២+០០ | ១២.០០០ |

| ល.រ | លេខផ្លូវ ចាស់ | លេខផ្លូវ ថ្មី | ខេត្តក្រុង | ចំនុចចាប់ផ្តើម | ចំនុចបញ្ចប់ | ប្រវែងផ្លូវ សរុប(គ.ម) |
|---|---|---|---|---|---|---|
| **ផ្លូវខេត្តក្នុងតំបន់១** | | | | | | |
| ៨៦ | ១៥៤ | ១៥៩ | បាត់ដំបង | ស្ពានថ្មថ្មី ប.គ២៥២+២០០ ( ផ.ជ៥) | វត្តតាម៉ឹម-ស្លក្រាម | ៧ .៥០០ |
| ៨៧ | គ្មាន | ១៥៩ក | បាត់ដំបង | ក្បាលខ្មោច ប.គ២៩៩+១០០ ( ផ.ជ៥) | អណ្តូងព្រីង ( ផ.៥៧) | ៦.៥០០ |
| ៨៨ | ១៥៧ | ១៥៩ខ | បាត់ដំបង | ថ្មគោល ប.គ៣១៧+៦០០ ( ផ.ជ៥) | បវិល-សំពៅលូន | ៩៩.០០០ |
| ៨៩ | គ្មាន | ១៥៩គ | បាត់ដំបង | បឹងព្រីង ប.គ៣៣១+៨០០ ( ផ.ជ៥) | ល្វា | ១២.០០០ |
| ៩០ | ១៦០ | ១៥៩ឃ | បាត់ដំបង | អូស្ងួត ប.គ៣៨២+០០ - ដូនអោកប.គ២០+៣០០ ( ផ.ជ៥) | ប៉ៃលិន | ១៣០.០០០ |
| ៩១ | ១៥៣ | ១៥៩ង | ប.ជ | កូនដំរី ប.គ៣៩៣+២០០ | ស្រុកមាឡៃ ប.គ៦៣+០០ | ៦៣.០០០ |
| ៩២ | គ្មាន | ១៦០ | កណ្តាល | រការកោង ប.គ៣៩+៣៨៤ ( ផ.ជ៦អា) | ស្ពានព្រែកក្តុយ-ព្រំប្រទល់កំពង់ចាម | ៤.២៥០ |
| ៩៣ | គ្មាន | ១៦១ | កណ្តាល | ភូមិថ្មី ឃុំស្វាយអំពៅ ប.គ៣៧+៧៦៥ | ភូមិពាមក្នុង ឃុំសំបួរមាស | ១៨.០០០ |
| ៩៤ | គ្មាន | ១៨០ | កណ្តាល | កំពង់ចំលងព្រែកតាមាក់ ( ផ.ជ៨) | សាលាស្រុកល្វាឯម-ទឹកឃ្លាំង | ៤៤.០០០ |
| ៩៥ | គ្មាន | ១៨១ | កណ្តាល | ព្រែកតាមាក់ ( ផ.ជ៨) | ស្រុកស៊ីធរ( ព្រំប្រទល់កំពង់ចាម) | ១០.២០០ |
| ៩៦ | គ្មាន | ១៨២ | កណ្តាល | ព្រះស្រែ ឃុំស៊ីធរ | ទន្លេតូច ( កំពង់ចំលង) | ៤.១០០ |
| ៩៧ | គ្មាន | ១៨៣ | កណ្តាល | ស្ពានព្រះគន្លង ( ផ.ជ៨) | ឃុំជ័យធំ ( ទន្លេតូច) | ១៤.១៥០ |
| ៩៨ | គ្មាន | ១៨៤ | កណ្តាល | កំពង់ពពិល ប.គ២២+៣៥៤ | សាលាស្រុកល្វាឯម-ទឹកឃ្លាំង | ២២.១៥៥ |
| ៩៩ | គ្មាន | ១២១០ | កណ្តាល | ស្លាង ប.គ២៧+៩៥០ ( ផ.ជ២១) | អូចារ ឃុំស្លាងភ្នំ | ៨.១៥០ |
| ១០០ | គ្មាន | ១២១២ | កណ្តាល | ស្វាយតានី ប.គ២៩+៩៥០ ( ផ.ជ២១) | ភូមិអង្គរ ឃុំក្រាំងយ៉ូវ | ១៨ .៦០០ |
| ១០១ | គ្មាន | ១២១៤ | កណ្តាល | ព្រែកអំបិល ប.គ៤២+៦០០( ផ.ជ២១) | អន្លង់តាសេក-ព្រំប្រទល់តាកែវ | ១០.៦០០ |
| ១០២ | គ្មាន | ១២១៦ | កណ្តាល | ព្រែកពែក ប.គ៥០+៦០៩ ( ផ.ជ២១) | ទំនប់ដាច់-ព្រែកម្សាស | ៣.៣០០ |
| ១០៣ | គ្មាន | ១៣១១ | កំពត | ផ្សារពានី ស្រុកឈូកវ្ពជ័យ ប.គ១២០+១០០( ផ.ជ៣១) | ឃុំព្រាំសេរ ប.គ១១២+៣០០ | ១៧ .០០០ |
| ១០៤ | ១១៦ | ១៣១៣ | កំពត | ស្រុកបន្ទាយមាស ប.គ១២៦+៥០០ ( ផ.ជ៣១) | ភូមិកន្ទប់ បណ្តោយព្រែក | ៤.២២០ |

| ល.រ | លេខផ្លូវ | | | ចំណុចចាប់ផ្តើម | ចំណុចបញ្ចប់ | ប្រវែងផ្លូវ |
|---|---|---|---|---|---|---|
| | ចាស់ | ថ្មី | ខេត្ត/ក្រុង | | | សរុប(គ.ម) |
| | | | | **ផ្លូវខេត្តក្នុងតំបន់១** | | |
| ១០៥ | ១១៧ | ១៣១៥ | កំពត | ឃុំកន្ទរ ប.គ១៣៤+០០ ( ផ.ជ៣១) | ឃុំព្រៃទន្លេ ( ព្រំប្រទល់វៀតណាម) | ១២.២០០ |
| ១០៦ | គ្មាន | ១៣៣០ | កែប | ប.គ២៤+៦០០ ( ផ.ជ៣៣) | លក | ១៧ .០០០ |
| ១០៧ | ១២០ | ១៣៣១ | កំពត | សាលាស្រុកកំពត ប.គ៥+២០០ ( ផ.ជ៣៣) | ឃុំកូនសត្វ-ស្រុកកំពត | ៦.៥៦០ |
| ១០៨ | គ្មាន | ១៣៣៣ | កែប | ចំការដូង ប.គ២១+៥០០ ( ផ.ជ៣៣) | ភ្នំវិល្លី ( ផ្លូវបំបែកចំការបី) | ៨.០០០ |
| ១០៩ | គ្មាន | ១៣៣៥ | កែប | ចំការចេក ប.គ២៧+៨០០ ( ផ.ជ៣៣) | ភ្នំវិល្លី ( ផ្លូវបំបែកចំការបី) | ៧ .០០០ |
| ១១០ | ១២៩ | ១៤៤០ | កំពង់ស្ពឺ | ប.គ២+២៥០ ( ផ.ជ៤៤) | បាត់ដឹង ( កំពង់ស្ពឺ) | ៣៦.៥៥០ |
| ១១១ | ១៣២ | ១៤៤១ | កំពង់ស្ពឺ | ភូមិក្រាំងចេក ប.គ១៦+០០ | ប.គ៤៣+៥០០ ( ផ.ជ៤៤) | ៣៨.០០០ |
| ១១២ | ១៣៣ | ១៤៤២ | កំពង់ស្ពឺ | រលាក់កងជើង ប.គ៨៣+៣៥ ( ផ.ជ៤៤) | ភូមិតាសី ( ពោធិ៍សាត់) | ៣៥.០០០ |
| ១១៣ | គ្មាន | ១៤៨០ | កោះកុង | ប.គ៩៤+០០ ( ផ.ជ៤៨) | ថ្មបាំង | ៣៨.០០០ |
| ១១៤ | ១៦១ | ១៤៨១ | កោះកុង | ប.គ១៤៩+៩៦០ ( ផ.ជ៤៨) | ប.គ១៥៦+០០ | ៥.០០០ |
| ១១៥ | គ្មាន | ១៤៨៣ | កោះកុង | ប.គ៣០១+០០ ( ផ.ជ៤៨) | ព្រំប្រទល់ថៃ | ៨.០០០ |
| ១១៦ | ១៣០ | ១៥១១ | កំពង់ស្ពឺ | ប.គ១៦+៣៥ ( ផ.ជ៥១) | ព្រៃកញ្ចៅ ប.គ១២+៩៩ ( ផ.ជ៥) | ១៨ .៧០០ |
| ១១៧ | គ្មាន | ១៥៧០ | បាត់ដំបង | ភ្នំព្រពើ ប.គ១៦+៨០០ ( ផ.ជ៥៧) | កំពីងពួយ-ភ្នំវែង-អូដូនពៅ | ៤០.០០០ |
| ១១៨ | ១៥៥ | ១៥៧១ | បាត់ដំបង | ប.គ២+៦០០ ( ផ.ជ៥៧) ពេទ្យ៧២ | បាណន់-ចេងមេន ជ័យ-ស្ទឹង | ៤៦.០០០ |
| ១១៩ | គ្មាន | ១៥៧២ | ប៉ៃលិន | រង្វង់មូលសួនកុមារ ប.គ៨៤+១៦៧ ( ផ.ជ៥៧) | ភ្នំពុត ប.គ៧៩+៩៩៨ | ៦.០០០ |
| ១២០ | គ្មាន | ១៥៧៣ | បាត់ដំបង | ភូមិកៀវ ប.គ៨៦+៦០០ ( ផ.ជ៥៧) | សំឡូត-ស្ទឹងក្រញូង | ៤០.០០០ |
| ១២១ | គ្មាន | ១៥៧៤ | ប៉ៃលិន | ភូមិរថក្រោះឆេះ ប.គ៩១+៤៤០ ( ផ.ជ៥៧) | ភ្នំគុយ | ១៥.៥០០ |
| ១២២ | គ្មាន | ១៥៧៥ | ប៉ៃលិន | ប.គ៦៧+៤៩៨ ( ផ.ជ៥៧) | ភូមិក្រចាប់ ប.គ៧៩+៩៩៨ | ១២.៥០០ |
| ១២៣ | គ្មាន | ១៥៧៧ | ប៉ៃលិន | វត្តអូរប្រាល ប.គ៨៧+៣០០ ( ផ.ជ៥៧) | បរតាំងស៊ូ ប.គ៩១+៨០០ | ៤.៥០០ |

| ល.រ | លេខផ្លូវ | | | ចំណុចចាប់ផ្តើម | ចំណុចបញ្ចប់ | ប្រវែងផ្លូវ |
|---|---|---|---|---|---|---|
| | ចាស់ | ថ្មី | ខេត្តក្រុង | | | សរុប(គ.ម) |
| **ផ្លូវខេត្តក្នុងតំបន់១** | | | | | | |
| ១២៤ | គ្មាន | ១កណ១ | កណ្តាល | ព្រែកដាច់ ប.គ ១៥+០០ (ផ.៦១១៨ក) | កំពង់កុង (ផ.៦១១០) | ២៤.៣៩០ |
| ១២៥ | គ្មាន | ១កណ២ | កណ្តាល | តាំងឫស្សី ប.គ៣+៦៥០ | ព្រះប្រសព្វ | ១២.៤៧៨ |
| ១២៦ | ១១៣ | ១តក១ | តាកែវ | វត្តព្រះធាតុ ប.គ១២+ ៤៧០(ផ.៦១១២) | ស្ពានពោធគាស៊ុយ | ១៥.៥០០ |
| ១២៧ | ២០៤ | ១តក២ | តាកែវ | ព្រៃល្វា ប.គ២២+១០០ | ប្រាសាទភ្នំដា | ២៥.០០០ |
| ១២៨ | ១៤២ | ១កឆ១ | កំពង់ឆ្នាំង | សំណល់រថភ្លើងស្តុកអាចម៍រមាស | ប.គ៤០+៧៨៧ | ១៣.៦៥៧ |
| ១២៩ | ២២១ | ១កឆ២ | កំពង់ឆ្នាំង | ភូមិកំពង់បឹង | សាលាកុកទ្រា | ៣២.០០០ |
| ១៣០ | ១៧៤ | ១ពស១ | ពោធិ៍សាត់ | កញ្ជៀង ប.គ៨+៧៦០ | ស្រែស្តុក | ១២.០០០ |
| ១៣១ | ១៥១ | ១បប១ | បាត់ដំបង | ក្បាលថ្នល់ ប.គ២៧១+១០០ | រាំងកេសី | ៨.៥០០ |
| ១៣២ | គ្មាន | ១បប២ | បាត់ដំបង | ភូមិពង្រ ប.គ៤៦+៤០០ | កំរៀង | ៥០.០០០ |
| ១៣៣ | គ្មាន | ១បប៣ | បាត់ដំបង | កំប្រង់៣០ | ភ្នំព្រឹក | ៦០.០០០ |
| | | | | | សរុប | ៣០១៧.០១៣ |

# ផ្លូវខេត្តដែលត្រូវរៀបចំជាថ្មី

## តំបន់ទី២ : ប៉ែកខាងជើងឈៀងខាងលិច (តំបន់ចន្លោះទន្លេសាប និង ទន្លេមេគង្គខាងលើ)

### កំពង់ធំ_សៀមរាប_ព្រះវិហារ_ឧត្តរមានជ័យ

| ល.រ | លេខផ្លូវ | | | ចំណុចចាប់ផ្ដើម | ចំណុចបញ្ចប់ | ប្រវែងផ្លូវ |
|---|---|---|---|---|---|---|
| | ចាស់ | ថ្មី | [illegible] | | | សរុប(គ.ម) |
| | | | | **ផ្លូវខេត្តក្នុងតំបន់២** | | |
| ១ | គ្មាន | ២៥០ | ប.ជ | ប.គ៣៩៤+០០ ( ផ.ជ៥) | អូបីជាន់ ប.គ១៩+០០ | ១៩.០០០ |
| ២ | គ្មាន | ២៦០ | កំពង់ចាម | រកាកោង ( ផ.ជ៦) | ពាមជីកង ( ផ.ជ៧០) | ៣៨.០០០ |
| ៣ | ២២៤ | ២៦០ក | កំពង់ចាម | ផ្អាវ ( ផ.ជ៦) | ស្ទឹន | ១៨.៦០០ |
| ៤ | គ្មាន | ២៦០ខ | កំពង់ចាម | ស្វាយពក ( ផ.ជ៦) | ទំរៀង | ៧ .៥០០ |
| ៥ | គ្មាន | ២៦១ | កំពង់ចាម | ផ្អាវ ( ផ.ជ៦) | ទំនប់ | ៥.៥០០ |
| ៦ | គ្មាន | ២៦១ក | កំពង់ចាម | ស្ទឹន ( ផ.ជ៦) | សង្កែពង | ២.៥០០ |
| ៧ | គ្មាន | ២៦១ខ | កំពង់ចាម | ស្ទើងជ័យ ( ផ.ជ៦) | កោះចំប៉ា | ១៤.០០០ |
| ៨ | គ្មាន | ២៦២ | កំពង់ចាម | ស្វាយមាស ( ផ.ជ៦) | បឹងណាយ-ថ្មពូន | ១៨.៦០០ |
| ៩ | ២២១ | ២៦៣ | កំពង់ធំ | ភូមិពុកយុក ប.គ១៥៩+០០ ( ផ.ជ៦) | ស្រុកកំពង់ឡេង ( ព្រំប្រទល់កំពង់ចាម) | ៣២.០០០ |
| ១០ | គ្មាន | ២៦៣ក | កំពង់ធំ | ស្ពានក្រហូង ប.គ២០៦+០០ ( ផ.ជ៦) | ភូមិជីមូស | ១៦.០០០ |
| ១១ | គ្មាន | ២៦៤ | កំពង់ធំ | តាំងគោក ប.គ៩៦+០០ | ឃុំជ្រនៀង | ៨.០០០ |
| ១២ | គ្មាន | ២៦៤ក | កំពង់ធំ | ផ្សាររលាង ប.គ១១០+០០ ( ផ.ជ៦) | ឃុំចំការអណ្ដូង | ៤.០០០ |
| ១៣ | គ្មាន | ២៦៤ខ | កំពង់ធំ | កំពង់ថ្ម ប.គ១៣១+០០ ( ផ.ជ៦) | ឃុំក្រយ៉ា | ២៥.០០០ |

| ល.រ | លេខផ្លូវ ចាស់ | លេខផ្លូវ ថ្មី | ខេត្តក្រុង | ចំណុចចាប់ផ្តើម | ចំណុចបញ្ចប់ | ប្រវែងផ្លូវ សរុប(គ.ម) |
|---|---|---|---|---|---|---|
| **ផ្លូវខេត្តក្នុងតំបន់២** | | | | | | |
| ១៤ | ២៣ | ២៦៤គ | កំពង់ធំ | តាំងក្រសាំង ប.គ១៤១+៣០០ ( ផ.ជ៦) | ទឹកអណ្តូង | ២៣.០០០ |
| ១៥ | គ្មាន | ២៦៤ឃ | កំពង់ធំ | ភូមិលាបទង ប.គ២១៧+០០ ( ផ.ជ៦) | ឃុំវិស័យ ស្រុកប្រាសាទបល្ល័ង្គ | ៤៥.០០០ |
| ១៦ | គ្មាន | ២៦៤ង | កំពង់ធំ | ប.គ២១៨ +១០០ ( ផ.ជ៦) | ព្រំប្រទល់ព្រះវិហារ | ៦៥.៨០០ |
| ១៧ | គ្មាន | ២៦៥ | កំពង់ធំ | ស្ទូង ប.គ២១៨+០០ ( ផ.ជ៦) | ឃុំម្ទុំសាក្រង-ពាមបាំង | ២៥.០០០ |
| ១៨ | គ្មាន | ២៦៥ក | សៀមរាប | កំពង់ក្តី ប.គ២៥៣+៤០០ ( ផ.ជ៦) | ទំនប់ស្ទូង | ១២.០០០ |
| ១៩ | ២០៨ | ២៦៥ខ | សៀមរាប | គោកធ្លក ប.គ២៧៩+០០ ( ផ.ជ៦) | អន្លង់សំណរ | ១០.០០០ |
| ២០ | ២០៧ | ២៦៥គ | សៀមរាប | ថ្នល់ចេក ប.គ២៧៩+៣២៥ ( ផ.ជ៦) | កំពង់ឃ្លាំង | ១៥.៧៦៨ |
| ២១ | គ្មាន | ២៦៥ឃ | សៀមរាប | ដីដែក ប.គ២៨៤+០២៥ ( ផ.ជ៦) | ស្រមធំ | ៨.០០០ |
| ២២ | ២០៦ | ២៦៥ង | សៀមរាប | អង្រ្កង ប.គ២៩៧+៣០០ ( ផ.ជ៦) | កំពង់ភ្លុក | ១៦.០០០ |
| ២៣ | គ្មាន | ២៦៦ | សៀមរាប | កំពង់ក្តី ប.គ២៥៤+៤០០ ( ផ.ជ៦) | ខ្វាវ | ៤២.០០០ |
| ២៤ | ២០៩ | ២៦៦ក | សៀមរាប | គោកធ្លកលើ ប.គ ២៥៤+៤០០ ( ផ.ជ៦) | ប.គ៤៨+០០ ( ផ.ជ៦៦) | ៣០.០០០ |
| ២៥ | ៦៥ | ២៦៦ខ | សៀមរាប | ដីដែក ប.គ២៨៤+០២៥ ( ផ.ជ៦) | ត្រពាំងព្រៃ ប.គ២៧+០០ ( ផ.ជ៦៦) | ១៩.០០០ |
| ២៦ | គ្មាន | ២៦៦គ | សៀមរាប | អង្រ្កង ប.គ២៩៧+៤០០ ( ផ.ជ៦) | ត្រាច | ១០.០០០ |
| ២៧ | ២០២ | ២៦៦ឃ | សៀមរាប | ពួក ប.គ៣៣០+៦០០ ( ផ.ជ៦) | មោង ( ផ.ជ៦៨) | ៤៥.០០០ |
| ២៨ | គ្មាន | ២៦៦ង | សៀមរាប | ពួក ប.គ៣៣០+៨០០ ( ផ.ជ៦) | ស្រែណូយ ប.គ៤៩+០០ ( ផ.ជ៦៤) | ៧៨.០០០ |
| ២៩ | គ្មាន | ២៦៧ | សៀមរាប | ពួក ប.គ៣៣០+៥០០ ( ផ.ជ៦) | ពាមតាអូ | ១២.០០០ |
| ៣០ | គ្មាន | ២៦៧ក | សៀមរាប | ក្រឡាញ់ ប.គ៣៦៩+០០ ( ផ.ជ៦) | សំបួរ | ១២.០០០ |
| ៣១ | ២០១ | ២៦៨ | សៀមរាប | សសរស្តម ប.គ៣៨៥+០០ ( ផ.ជ៦) | អង្គរជុំ ប.គ៣០+០០ ( ផ.ជ២៦៨ខ) | ២៥.៥០០ |

| ល.រ | លេខផ្លូវ | | | ចំនុចចាប់ផ្តើម | ចំនុចបញ្ចប់ | ប្រវែងផ្លូវ |
|---|---|---|---|---|---|---|
| | ចាស់ | ថ្មី | ខេត្តគ្រប់គ្រង | | | សរុប(គ.ម) |
| **ផ្លូវខេត្តក្នុងតំបន់២** | | | | | | |
| ៣២ | គ្មាន | ២៦៨ក | សៀមរាប | ស្រណាល ប.គ៣៥៧+៧០០ ( ផ.ជ៦) | សែនសុក ប.គ២០+០០ ( ផ.ជ៦៨) | ២៥.០០០ |
| ៣៣ | គ្មាន | ២៦៨ខ | ប.ជ | ព្រៃមិន ប.គ៣៨៤+០០ ( ផ.ជ៦) | ស្រុកភ្នំស្រុក ប.គ១៧+៤០០ | ១៧ .៤០០ |
| ៣៤ | ២២៣ | ២៧០ | កំពង់ចាម | ទន្លេកំពង់ចាម | ពាមជីកង ( ផ.ជ៧០) | ២២.៥០០ |
| ៣៥ | ២២៣ | ២៧១ | កំពង់ចាម | កំពង់ចាម | ស្ទឹងត្រង់ | ៣០.០០០ |
| ៣៦ | គ្មាន | ២៧៣ | កំពង់ចាម | ទន្លេអុំ | វាលត្រៀល | ១១.៥០០ |
| ៣៧ | ២៦ | ២៥៦១ | ប.ជ | ស្រុកថ្មពួក ( ផ.ជ៥៦) | បឹងត្រកួន ប.គ២៦+០០ | ២៦.០០០ |
| ៣៨ | គ្មាន | ២៦២០ | កំពង់ចាម | ឃុំគរ | បុស្សខ្នុរ | ១៤.៧០០ |
| ៣៩ | ២២០ | ២៦២០ក | កំពង់ធំ | ភូមិកូនត្នោត ប.គ១៨១+០០ ( ផ.ជ៦២) | ឃុំមានជ័យ ស្រុកសណ្តាន់ | ៤០.០០០ |
| ៤០ | គ្មាន | ២៦២១ | ព្រះវិហារ | ភូមិស្វាយបាត់ - ឃុំរំដោះ - ស្រុករវៀង ( ផ.ជ៦២) | ឃុំណេសិរ្ស - ស្រុកសង្គមថ្មី ( ផ.ជ៦៦អា) | ៥៧ .០០០ |
| ៤១ | ២១៩ | ២៦២២ | កំពង់ធំ | ឃុំសាលាវិស័យ ប.គ១៩៤+៥០០ ( ផ.ជ៦២) | ស្រុកសណ្តាន់ | ៧៨ .០០០ |
| ៤២ | ២១៨ | ២៦២២ក | កំពង់ធំ | ប្រាសាទសំបូរ | ភូមិថ្នល់កែង-ឃុំរុងរឿង-ស្រុករវៀង ( ព្រះវិហារ) | ១២០.០០០ |
| ៤៣ | ២១០ | ២៦២៣ | ព្រះវិហារ | ភូមិថ្នល់បែក ឃុំថ្មី ស្រុកគូលេន ប.គ១៥២+០០( ផ.ជ៦២) | ស្រុកស្វាយលើ ( ព្រំប្រទល់សៀមរាប) | ៨៦.០០០ |
| ៤៤ | ២១៧ | ២៦២៤ | ព្រះវិហារ | ភូមិស្វាយបាត់ ឃុំរំដោះ ស្រុករវៀង ( ផ.ជ៦២) | ឃុំរស្មី ស្រុករវៀង | ៥៥.០០០ |
| ៤៥ | ២១២ | ២៦២៥ | ព្រះវិហារ | ភូមិសាអែម-កន្ទួត ប.គ២៧០+០០( ផ.ជ៦២) | ភូមិបរ ស្រុកត្រពាំងប្រាសាទ ( ឧត្តរមានជ័យ-ព្រំប្រទល់ព្រះវិហារ) | ២៥.០០០ |
| ៤៦ | គ្មាន | ២៦២៦ | ព្រះវិហារ | ភូមិក្រាំងដូង ឃុំព្រះឃ្លាំង ស្រុកត្បែងមានជ័យ( ផ.ជ៦២) | ឃុំស្លាង ស្រុកជ័យសែន | ៣០.០០០ |
| ៤៧ | ២១៤ | ២៦២៨ | ព្រះវិហារ | ភូមិកំពង់ចំលង ឃុំកំពង់ប្រណាក ស្រុកត្បែងមានជ័យ( ផ៦២) | ថាឡាបរិវ៉ាត់ ( ទីរួមខេត្តស្ទឹងត្រែង ផ.ជ៦៦អា) | ១៣៤.០០០ |

| ល.រ | លេខផ្លូវ ចាស់ | ថ្មី | ខេត្តក្រុង | ចំនុចចាប់ផ្តើម | ចំនុចបញ្ចប់ | ប្រវែងផ្លូវ សរុប(គ.ម) |
|---|---|---|---|---|---|---|
| | | | | **ផ្លូវខេត្តក្នុងតំបន់២** | | |
| ៤៨ | ២១១+ ២១២ | ២៦២៨ក | ព្រះវិហារ | ផ្លូវបំបែកជាំក្សាន្ត-សាអែម ប.គ២០៧+០០ ( ផ.ជ៦២) | ភូមិសង្កែរ ឃុំសង្កែរ១ ស្រុកឆែប ( ផ.ខ២៦២៨) | ១៣៣.០០០ |
| ៤៩ | គ្មាន | ២៦២៨ខ | ព្រះវិហារ | អក្សរគេ ( ផ.ជ៦២) | តាត្រាវ ( ព្រំប្រទល់ថៃ) | ៨.០០០ |
| ៥០ | ២០៣ | ២៦៤០ | សៀមរាប | ព្រះដាក់ ប.គ១០+៣៥០ ( ផ.ជ៦៤) | ភ្នំគូលប.គ១០+៥០០ ( ផ.ខ២៦៤៤) | ១៤.០០០ |
| ៥១ | គ្មាន | ២៦៤០ក | សៀមរាប | ភ្នំបូក ប.គ១៣+០០ ( ផ.ជ៦៤) | រុនតាអែក ប.គ២៣+០០ | ២៥.៥០០ |
| ៥២ | គ្មាន | ២៦៤០ខ | សៀមរាប | បន្ទាយស្រី ប.គ២៦+៣៥០ ( ផ.ជ៦៤) | បំបែកភ្នំគូលេន | ១៧ .៥០០ |
| ៥៣ | គ្មាន | ២៦៤១ | សៀមរាប | ខាសណ្តាយ ប.គ១៨+៣២៦ ( ផ.ជ៦៤) | ភាំន | ៤២.០០០ |
| ៥៤ | ២០៤ | ២៦៤២ | សៀមរាប | តាកូស ប.គ១៦+៣៥០ ( ផ.ជ៦៤) | ភ្នំគូលេន | ២៥.០០០ |
| ៥៥ | ២០៥ | ២៦៤៤ | សៀមរាប | ឃុនរាម ប.គ៣៧+០០ ( ផ.ជ៦៤) | ត្រពាំងព្រៃ ប.គ២៥+០០ ( ផ.ជ៦៦) | ២៧ .០០០ |
| ៥៦ | គ្មាន | ២៦៤៦ | សៀមរាប | ស្រែណូយ ប.គ៤៩+០០ | ស្វាយលើ | ៤៥.០០០ |
| ៥៧ | ១៧៤ | ២៦៤៨ | ឧ.ជ | អន្លង់វែង ប.គ៤៦៧+០០ ( ផ.ជ៦៤) | ប.គ៥០៧+០០ ( ព្រំប្រទល់ព្រះវិហារ) | ៤០.០០០ |
| ៥៨ | គ្មាន | ២៦៦១ | សៀមរាប | ស្វាយលើ | ស្រយង់ | ២១.០០០ |
| ៥៩ | ២១៣ | ២៦៦៣ | ព្រះវិហារ | ភូមិតាំងត្រក់-ឃុំរបេប-ស្រុករវៀង ( ផ.ជ៦៦អា) | ភូមិកំពង់ស្រឡៅ -ឃុំកំពង់ស្រឡៅ១-ស្រុកឆែប ( ព្រំប្រទល់ឡាវ) | ១៤៤.២០០ |
| ៦០ | គ្មាន | ២៧១០ | កំពង់ចាម | អូស្វាយ | ព្រាន | ៩.៥០០ |
| ៦១ | គ្មាន | ២៧១២ | កំពង់ចាម | តាអុង | ចំរើនផល | ៤.០០០ |
| ៦២ | ២២២ | ២៧១៤ | កំពង់ចាម | ថ្នល់បែក | ស្ទឹងត្រង់ | ៣៣.០០០ |

| ល.រ | លេខផ្លូវ | | | ចំនុចចាប់ផ្តើម | ចំនុចបញ្ចប់ | ប្រវែងផ្លូវ |
|---|---|---|---|---|---|---|
| | ចាស់ | ថ្មី | ខេត្ត/ក្រុង | | | សរុប(គ.ម) |
| | | | | **ផ្លូវខេត្តក្នុងតំបន់២** | | |
| ៦៣ | គ្មាន | ២៧១៦ | កំពង់ចាម | ថ្នល់បែក | ពន្លឺភូមិ៣ | ៦.០០០ |
| ៦៤ | គ្មាន | ២៧១៨ | កំពង់ធំ | ភូមិយ៉ាទៀង ប.គ១៣០+០០ ( ផ.ជ៧១) | សណ្តាន់ | ១២០.០០០ |
| ៦៥ | ១៧១ | ២៦៨០ | ឧ.ជ | គីរីវ័ន្ត ប.គ៤០៧+០០ ( ផ.ជ៦៨) | ស្រុកអន្លង់វែង ប.គ៤៦៧+០០ | ៦០.០០០ |
| ៦៦ | ១៨១ | ២៦៨១ | ឧ.ជ | ចុងកាល់ ប.គ២៧៧+០០ ( ផ.ជ៦៨) | បូសស្បូវ ប.គ៣៩៥+០០ ( ផ.ជ៥៦) | ៤១.៥០០ |
| ៦៧ | ១៨៣ | ២៦៨៣ | ឧ.ជ | ប.គ៤០៧+០០ ( ផ.ជ៦៨) | ថ្នល់ដាច់ ប.គ៤៣៩+០០ | ៣២.០០០ |
| ៦៨ | ២១៦ | ២ព្រវ១ | ព្រះវិហារ | ភូមិកំពង់ពុទ្រា-ឃុំកំពង់ពុទ្រា-ស្រុកជ័យសែន | ព្រំប្រទល់ស្ទឹងត្រែង | ៦៦.០០០ |
| ៦៩ | ២១៥ | ២ព្រវ២ | ព្រះវិហារ | ឃុំពុទ្រា | ឆែប ( ផ.ខ២៦២៨) | ១២.០០០ |
| ៧០ | គ្មាន | ២ព្រវ៣ | ព្រះវិហារ | ភូមិពោធិ៍ ឃុំកំពង់ប្រណាក ស្រុកត្បែងមានជ័យ | ភូមិនាអាស់ ស្រុកជាំក្សាន្ត ( ផ.ខ២៦២៨ក) | ៤៦.០០០ |
| ៧១ | គ្មាន | ២ព្រវ៤ | ព្រះវិហារ | ឃុំជាំក្សាន្ត ស្រុកជាំក្សាន្ត | អក្សរពេ ( ផ.ជ៦២) | ៣០.០០០ |
| ៧២ | គ្មាន | ២ព្រវ៥ | ព្រះវិហារ | ភូមិជាំក្សាន្ត ឃុំជាំក្សាន្ត ស្រុកជាំក្សាន្ត | ព្រំប្រទល់ថៃ | ២៥.០០០ |
| | | | | | សរុប | ២៨៣៦.៥៦៨ |

# ផ្លូវខេត្តដែលត្រូវរៀបចំជាថ្មី

## តំបន់ទី៣ : ប៉ែកខាងកើត (តំបន់ចន្លោះមេគង្គខាងលើ និង ទន្លេមេគង្គខាងក្រោម)

### កំពង់ចាម_ក្រចេះ_ស្ទឹងត្រែង_មណ្ឌលគិរី_រតនៈគិរី_ព្រៃវែង_ស្វាយរៀង

| ល.រ | លេខផ្លូវ ចាស់ | លេខផ្លូវ ថ្មី | ឈ្មោះខេត្ត | ចំណុចចាប់ផ្តើម | ចំណុចបញ្ចប់ | ប្រវែងផ្លូវ សរុប(គ.ម) |
|---|---|---|---|---|---|---|
| **ផ្លូវខេត្តក្នុងតំបន់៣** | | | | | | |
| ១ | គ្មាន | ៣១០ | ព្រៃវែង | អ្នកលឿង-ពាមជរ ប.គ៦១+០០ ( ផ.ជ១) | ព្រំប្រទល់វៀតណាម | ៤៣.០០០ |
| ២ | ៣៣០ | ៣១០ក | ព្រៃវែង | កំពង់ត្រួស ប.គ៩៩+៥០០ ( ផ.ជ១) | កំពង់ជ្រៃ | ៥.៦៤០ |
| ៣ | ២ | ៣១០ខ | ស្វាយរៀង | ភូមិថ្នល់ ប.គ១១៦+៣០០ ( ផ.ជ១) | ឃុំស្វាយធំ ( ព្រំប្រទល់ព្រៃវែង) | ៣៧.៣០០ |
| ៤ | ៣២៩+ ៣៣២ | ៣១០គ | ស្វាយរៀង | ក្រោលគោ ប.គ១០៣+៧៥០ ( ផ.ជ១) | ភូមិតានូ-ឃុំចំបក់ | ២៨.៨៩០ |
| ៥ | ៣១៨ | ៣១១ | ព្រៃវែង | កំពង់សឹង ប.គ៧០+២០០ ( ផ.ជ១) | ភូមិឈើកាច់ប.គ៩+៤០០ | ៩.៤០០ |
| ៦ | ៣៣៣ | ៣១២ | ស្វាយរៀង | ភូមិថ្នល់-ឃុំចេក ប.គ១២២+៨៥០ ( ផ.ជ១) | ភូមិជៀសឬស្សី -ឃុំចំលង | ៩.៣០០ |
| ៧ | ៣ | ៣១២ក | ស្វាយរៀង | ភូមិចុងព្រែក ( ផ.ជ១) | វត្តព្រៀង-ឃុំចំបក់ | ១៤.៣០០ |
| ៨ | ៣១៧ | ៣១៣ | ព្រៃវែង | កោះអណ្តើក ប.គ៩៣+៩៣០ ( ផ.ជ១) | ព្រែកឈ្លៀង ប.គ១៩+៩៨៨ ( ផ.ជ១១) | ៤០.៨៤៥ |
| ៩ | ៣៣៤+៧ | ៣១៤ | ស្វាយរៀង | ភូមិរោងបន្ទៃ ទីរួមខេត្ត ( ផ.ជ១) | ឃុំទួលស្តី | ៦៣.៣៣០ |
| ១០ | ៣៣៦ | ៣១៤ក | ស្វាយរៀង | ផ្សារប្រសូត្រ ប.គ១៣៥+៧១៩ ( ផ.ជ១) | ភូមិព្រៃស្លឹ-ឃុំថ្មី ( ព្រំប្រទល់វៀតណាម) | ២៤.៥៥០ |
| ១១ | ៤ | ៣១៤ខ | ស្វាយរៀង | តុលាការខេត្ត ប.គ១២៤+៥០០ ( ផ.ជ១) | ប.គ១២៨+០០ | ៤.៨២០ |
| ១២ | ៣២១ | ៣១៥ | ស្វាយរៀង | ក្រោលគោ ប.គ១០៣+៧០០ ( ផ.ជ១) | ភូមិថ្នាន-ឃុំអង្គតាសូ | ១១.១១០ |
| ១៣ | ១ | ៣១៥ក | ស្វាយរៀង | ផ្សារស្វាយជ្រំ ប.គ១១៤+២០០ ( ផ.ជ១) | ភូមិជ្រៃ-ឃុំអង្គតាសូ | ៩.៣៩០ |
| ១៤ | ៦ | ៣១៦ | ស្វាយរៀង | ភូមិស្វាយតាយាន ( ផ.ជ១) | ភូមិខ្សែត-ឃុំខ្សែត | ១៤.៥០០ |

| ល.រ | លេខផ្លូវ | | | ចំនុចចាប់ផ្តើម | ចំនុចបញ្ចប់ | ប្រវែងផ្លូវ |
|---|---|---|---|---|---|---|
| | ចាស់ | ថ្មី | [illegible] | | | សរុប (គ.ម) |
| **ផ្លូវខេត្តក្នុងតំបន់៣** | | | | | | |
| ១៥ | ៣១៩ | ៣១៧ | ស្វាយរៀង | ភូមិព្រៃឆ្លាក់ ប.គ១២៤+៤០០ ( ផ.ជ១) | កំចាយមា ( ព្រំប្រទល់ព្រៃវែង) | ៥៨.៨៦០ |
| ១៦ | ៥ | ៣១៧ក | ស្វាយរៀង | ភូមិទុងលៀង ប.គ១៣១+២០០ ( ផ.ជ១) | ភូមិស្រម៉-ឃុំស្វាយរំពារ | ៩.០០០ |
| ១៧ | ៣២៨ | ៣១៧ខ | ស្វាយរៀង | ភូមិទុងលៀង ប.គ១៣៥+៤៥៥ ( ផ.ជ១) | ភូមិទួលអង្គ-ឃុំស្វាយរំពារ | ១៦.២០០ |
| ១៨ | ៣៣៧ | ៣១៨ | ស្វាយរៀង | ជីភូ ប.គ១៤៩+១៥០ ( ផ.ជ១) | ភូមិទួលស្តី -ទួលស្តី | ៣៤.០០០ |
| ១៩ | ៣៣៩ | ៣១៨ក | ស្វាយរៀង | ព្រៃកូនគតី ប.គ១៦០+២០០ ( ផ.ជ១) | ឃុំប្រាសាទ ( ព្រំប្រទល់វៀតណាម) | ១៨.០០០ |
| ២០ | ៣៣៨ | ៣១៩ | ស្វាយរៀង | ភូមិព្រៃធ្នក ប.គ១៥៥+៥០០ ( ផ.ជ១) | សាលារៀនពពែត | ១៤.៤០០ |
| ២១ | គ្មាន | ៣៧០ | កំពង់ចាម | សួង | ពុទ្រា | ៣០.០០០ |
| ២២ | គ្មាន | ៣៧០ក | កំពង់ចាម | ដងកាំបិត | ជូនតី | ១៣.៥០០ |
| ២៣ | គ្មាន | ៣៧០ខ | កំពង់ចាម | កណ្តុរជ្រៃ | គោកល្វៀងគានី | ៦.០០០ |
| ២៤ | គ្មាន | ៣៧០គ | កំពង់ចាម | កោងកាង ( ផ្សារស្ទឹង) | កន្ទួត-ព្រៃទទឹង-ក្បាលដំរី-បុស្សចេក | ២៧ .៥០០ |
| ២៥ | ៣០៨ | ៣៧១ | កំពង់ចាម | ទន្លេបិត( កំពង់ចាម - ព្រំប្រទល់កណ្តាល) | ក្រចេះ | ១៣៥.០០០ |
| ២៦ | គ្មាន | ៣៧១ក | កំពង់ចាម | ថ្នល់ទទឹង | ទឹកចេញ | ៤.០០០ |
| ២៧ | គ្មាន | ៣៧១ខ | កំពង់ចាម | ជប់ | ភូមិ៨-១០ | ១៦.០០០ |
| ២៨ | គ្មាន | ៣៧១គ | កំពង់ចាម | ភូមិថ្នល់ថ្មី | សង្គមថ្មី | ៥.០០០ |
| ២៩ | គ្មាន | ៣៧២ | កំពង់ចាម | កោង( សាលាស្រុកក្រែក) | ស្ទឹងកំចាយមា ( ព្រំប្រទល់ព្រៃវែង) | ២២.៥០០ |
| ៣០ | ៣១៣ | ៣៧២ក | កំពង់ចាម | សាលាបឋមសិក្សាមេមត់ | សូតី ( ព្រំប្រទល់វៀតណាម) | ៣០.០០០ |
| ៣១ | គ្មាន | ៣៧២ខ | កំពង់ចាម | ជាមទ្រៀក | សាទុម ( ព្រំប្រទល់វៀតណាម) | ២៨.០០០ |
| ៣២ | គ្មាន | ៣៧៣ | កំពង់ចាម | ស្រឡប់ | ចានគួង-ពងទឹក | ២៧ .៥០០ |
| ៣៣ | គ្មាន | ៣៧៣ក | កំពង់ចាម | កណ្តុរជ្រៃ | ជ័យនិគម-ពន្ធាក | ១៥.០០០ |

| ល.រ | លេខផ្លូវ ចាស់ | លេខផ្លូវ ថ្មី | ឆ្លងកាត់ខេត្ត | ចំណុចចាប់ផ្ដើម | ចំណុចបញ្ចប់ | ប្រវែងផ្លូវ សរុប(គ.ម) |
|---|---|---|---|---|---|---|
| | | | | **ផ្លូវខេត្តក្នុងតំបន់៣** | | |
| ៣៤ | គ្មាន | ៣៧៣ខ | កំពង់ចាម | កោងកាង ( ផ្សារស្ទឹង) | ពាំពេលចុហជាច | ១៥.០០០ |
| ៣៥ | ៣១១ | ៣៧៣គ | កំពង់ចាម | ប.គ២០១+០៥០ ( ផ.ជ៧) | ឆ្លូង ( ផ.ជ៧) | ៧០.០០០ |
| ៣៦ | ៣១២ | ៣៧៣ឃ | កំពង់ចាម | មេមត់ | សំពៅលូន ( ព្រំប្រទល់ក្រចេះ) | ១៤.០០០ |
| ៣៧ | ៣១០ | ៣៧៤ | ក្រចេះ | ស្នួល | នីល ( ស្រុកស្នួល) | ១២.០០០ |
| ៣៨ | ៣០៩ | ៣៧៥ | ក្រចេះ | ស្វាយជ្រះ ( ស្រុកស្នួល) | ឆ្លូង | ៥១.០០០ |
| ៣៩ | ៣០៦ | ៣៧៥ក | ក្រចេះ | សណ្ដាន់ | ព្រំប្រទល់មណ្ឌលគិរី | ១៣.០០០ |
| ៤០ | ៣០៥ | ៣៧៥ខ | ក្រចេះ | ប.គ៤៧៥+០០ | សំបូរ | ២៥.០០០ |
| ៤១ | ៣០៧ | ៣៧៦ | ក្រចេះ | ស្រែរនាម ប.គ២៨១+០០ | ព្រំប្រទល់មណ្ឌលគិរី | ៩៤.០០០ |
| ៤២ | ៣០៥ | ៣៧៦ក | ក្រចេះ | ប.គ៤៧៥+០០ | កោះនាគ ព្រំប្រទល់មណ្ឌលគិរី ( ផ.ជ៧៦) | ១១០.០០០ |
| ៤៣ | ៣០១ | ៣៧៨ | ស្ទឹងត្រែង | ផ.ជ៧ | ព្រំប្រទល់រតនៈគិរី | ៧៤.០០០ |
| ៤៤ | ៣០១ | ៣៧៨ក | រតនៈគិរី | សៀមបាំង ប.គ៦០៥+០០ ( ផ.ជ៧) | វិនសៃ ប.គ៦២៦+០០ | ២១.០០០ |
| ៤៥ | ៣១៦ | ៣១១០ | ព្រៃវែង | ស្វាយអន្ទរ ប.គ៤៤+១១២ ( ផ.ជ១១) | កំចាយមា ប.គ៣៥+៨៨០ | ៣៥.៨០០ |
| ៤៦ | ៣១៥ | ៣១១១ | ព្រៃវែង | តាគរ ប.គ៣៥+៤១៥ ( ផ.ជ១១) | ប.គ៣៦+៨០០ | ៣៦.៨០០ |
| ៤៧ | គ្មាន | ៣១១២ | កំពង់ចាម | អូរាំងឪ | ទួលសុភី | ៣៥.០០០ |
| ៤៨ | គ្មាន | ៣១១៥ | កំពង់ចាម | អូរាំងឪ | មាន-កំពង់បឹង-មហាលាភ | ២៥.០០០ |
| ៤៩ | គ្មាន | ៣១១៧ | កំពង់ចាម | ពាមជាំង | ក្បាលទឹក | ៥.០០០ |

| ល.រ | លេខផ្លូវ ចាស់ | លេខផ្លូវ ថ្មី | លេខផ្លូវ ខេត្តក្រុង | ចំណុចចាប់ផ្ដើម | ចំណុចបញ្ចប់ | ប្រវែងផ្លូវ សរុប(គ.ម) |
|---|---|---|---|---|---|---|
| **ផ្លូវខេត្តក្នុងតំបន់៣** | | | | | | |
| ៥០ | ៣២៦+ ៣២៧ | ៣១៣០ | ស្វាយរៀង | ផ្សារជីភូ ប.គ១៤៩+១០០ | ឃុំកំពង់ចក ( ផ.ជ១៣) | ៣៧ .៩៩៧ |
| ៥១ | ៣២២ | ៣១៣១ | ស្វាយរៀង | ភូមិក្រញូង - ឃុំថ្មីដា ប.គ៣៤+៣៦៥ | ភូមិកំពង់ត្រាច ( ផ.ជ១៣) | ៩.៩៧០ |
| ៥២ | ៣២៥ | ៣១៣២ | ស្វាយរៀង | ភូមិសង្កែ-ឃុំសង្កែ ប.គ១៦+៨៥០ ( ផ.ជ១៣) | ឃុំបុស្សមន ( ព្រំប្រទល់វៀតណាម) | ១០.៣៥០ |
| ៥៣ | ៣២៤ | ៣១៣៤ | ស្វាយរៀង | ភូមិត្រពាំងធំ-ឃុំអង្គប្រស្រែ ( ផ.ជ១៣) | ឃុំដូង ( ព្រំប្រទល់វៀតណាម) | ៧ .៣៥០ |
| ៥៤ | ៣២៣ | ៣១៣៦ | ស្វាយរៀង | ផ្លូវលំពាម-ភូមិត្រពាំងធំ-ឃុំអង្គប្រស្រែ( ផ.ជ១៣) | ពាមមេត្រី ឃុំដូង | ១២.១០០ |
| ៥៥ | គ្មាន | ៣៧៣០ | កំពង់ចាម | វាលតូច | ស្វាយបាក់ | ១០.០០០ |
| ៥៦ | គ្មាន | ៣៧៣១ | កំពង់ចាម | ដីបែ | ខ្វាយ | ៥.០០០ |
| ៥៧ | គ្មាន | ៣៧៦០ | មណ្ឌលគិរី | ឡាប៉ាកេ ( ផ.ជ៧៦) | អូរជ្រៃម៉ាំង ស្រុកកែវសីមា | ១០.០០០ |
| ៥៨ | គ្មាន | ៣៧៦១ | មណ្ឌលគិរី | ឡាប៉ាកេ ( ផ.ជ៧៦) | ស្រុកកែវសីមា | ៤៧ .០០០ |
| ៥៩ | ៣៤៣ | ៣៧៦២ | មណ្ឌលគិរី | មណ្ឌលគិរីក្រុង ( ផ.ជ៧៦) | ដាក់ដាំបូប្រាំង-ស្រុកអូររាំង | ២៨.០០០ |
| ៦០ | ៣៤៥ | ៣៧៦៣ | មណ្ឌលគិរី | មណ្ឌលគិរីក្រុង ( ផ.ជ៧៦) | ឃុំមេម៉ង់-ស្រុកកែវសីមា | ៤៥.០០០ |
| ៦១ | ៣៤៤ | ៣៧៦៤ | មណ្ឌលគិរី | មណ្ឌលគិរីក្រុង ( ផ.ជ៧៦) | ឃុំប៊ូស្រា -ស្រុកពេជដា | ៣៣.០០០ |
| ៦២ | ៣០៤ | ៣៧៦៦ | រតនៈគិរី | លំផាត់ ប.គ៥៧៤+៥០០ ( ផ.ជ៧៦) | ឃុំសែង ប.គ៦១៥+៥០០ ( ផ.ជ៧៨) | ៤៥.០០០ |
| ៦៣ | ៣០២ | ៣៧៦៨ | រតនៈគិរី | អូជុំ ប.គ៦២១+១០០ ( ផ.ជ៧៦) | ប.គ៦៥១+១០០ | ៣០.០០០ |
| ៦៤ | ៧៦ខ | ៣៧៦៨ក | រតនៈគិរី | ប.គ៦៨១+០០ ( ផ.ជ៧៦) | ប.គ៧១១+០០ | ៣០.០០០ |
| ៦៥ | ៣០៤ក១ | ៣៧៨០ | រតនៈគិរី | ភូមិស្វាយ ប.គ៥៨៧+០០ ( ផ.ជ៧៨) | អូរសៀងលើ ប.គ៦១៤+០០ | ២៧ .០០០ |
| ៦៦ | ៣០៤ក២ | ៣៧៨១ | រតនៈគិរី | ភ្នំស្វាយ ប.គ៥៨៧+០០ ( ផ.ជ៧៨) | ឃុំហាត់ប៉ក់ ប.គ៦២៧+០០ | ៤០.០០០ |

| ល.រ | លេខផ្លូវ | | | ចំណុចចាប់ផ្ដើម | ចំណុចបញ្ចប់ | ប្រវែងផ្លូវ |
|---|---|---|---|---|---|---|
| | ចាស់ | ថ្មី | ស្ថិតក្នុងខេត្ត | | | សរុប(គ.ម) |
| **ផ្លូវខេត្តក្នុងតំបន់៣** | | | | | | |
| ៦៧ | ៣០៣ខ | ៣៧៨២ | រតនៈគីរី | ប៉ាកធំ ប.គ៦៥៤+០០ ( ផ.៨៧៨) | អូលាវ ប.គ៧២៤+០០ | ៧០.០០០ |
| ៦៨ | ៣០៣ | ៣៧៨៣ | រតនៈគីរី | ប៉ាកែវ ប.គ៦១៧+៥០០ ( ផ.៨៧៨) | បរខាំ ប.គ៦៥៥ +៥០០ | ៣៨.០០០ |
| ៦៩ | ៣០៣ក | ៣៧៨៥ | រតនៈគីរី | ប៉ាកធំ ប.គ៦៥៤+០០ ( ផ.៨៧៨) | ប.គ៧៤៤+០០ ( ផ.៨៧៦) | ៩០.០០០ |
| ៧០ | ៣១៤ | ៣៣វ១ | ព្រៃវែង | ព្រៃព្នៅ ប.គ១៨+២៥០ | ស៊ីធរកណ្ដាល ប.គ៣៩+៥៨០ | ២១.៨០០ |
| ៧១ | ៣៣១ | ៣ស្វរ១ | ស្វាយរៀង | ឃុំគួស | ភូមិក្រសាំងជ្រុំ-ឃុំគ្រួស | ៨ .១១០ |
| ៧២ | ៣៣៥ | ៣ស្វរ២ | ស្វាយរៀង | វត្តពោធិ៍ម្រទ្រី ប.គ២+៨៧០ | ឃុំស៊ំយ៉ុង ( ព្រំប្រទល់វៀតណាម) | ១៣.៥៥០ |
| ៧៣ | ៨ | ៣ស្វរ៣ | ស្វាយរៀង | ភូមិព្រៃតគីរ | ភូមិក្បាលថ្នល់ | ១៥.២០០ |
| ៧៤ | ៣២០ | ៣ស្វរ៤ | ស្វាយរៀង | ភូមិធ្លក-ឃុំធ្លក | ឃុំស្វាយយា | ១១ .៨០០ |
| ៧៥ | ៣០៤ខ | ៣រត១ | រតនៈគីរី | ឃុំសេដា ប.គ៥៩៧+៥០០ | ភូមិកោះសាន ប.គ៦២៧+៥០០ | ៣០.០០០ |
| | | | | | **សរុប** | **២១០៥.៦០២** |

កំណត់សំគាល់ :

| | | | | | |
|---|---|---|---|---|---|
| ១. ស្វាយរៀង | = ស្វរ | ៩ . ពោធិ៍សាត់ | = ពស | | |
| ២. សៀមរាប | = សរ | ១០ . បាត់ដំបង | = បប | ១៨ . កោះកុង | = កក |
| ៣. ព្រៃវែង | = ពវ | ១១ . បន្ទាយមានជ័យ | = បជ | ១៩ . ក្រុងកំពង់សោម | = កស |
| ៤. ព្រះវិហារ | = ព្រវ | ១២ . ឧត្ដរមានជ័យ | = ឧជ | ២០ . ក្រុងកែប | = កប |
| ៥ . កំពង់ឆ្នាំង | = កឆ | ១៣ . មណ្ឌលគីរី | = មណគ | ២១ . កំពត | = កព |
| ៦. កំពង់ធំ | = កធ | ១៤ . រតនៈគីរី | = រតគ | ២២ .ប៉ៃលិន | = បល |
| ៧. កំពង់ចាម | = កច | ១៥ . ភ្នំពេញ | = ភព | ២៣ .តាកែវ | = តក |
| ៨ . កំពង់ស្ពឺ | = កស្ព | ១៦ . ក្រចេះ | = ក្រច | ២៤ .កណ្ដាល | = កណ |

ភ្នំពេញ.ថ្ងៃទី30 ខែ 06 ឆ្នាំ២០០៤

នាយក នាយកដ្ឋានផ្លូវថ្នល់

លឹម_ស៊ីដេនីន

# តារាងឧបសម្ព័ន្ធទី២

## កំរិតកំណត់ទំងន់រថយន្តដឹកជញ្ជូនអនុញ្ញាតិធ្វើចរាចរតាមក្រុមបណ្តាញផ្លូវខេត្ត

| ល.រ | ប្រភេទរថយន្តដឹកជញ្ជូន | ទំងន់សរុបអតិបរមា រថយន្តដឹកជញ្ជូនអនុញ្ញាតិ |
|---|---|---|
| ១ |  | ១៦ តោន |
| ២ |  | ២០ តោន |

### ផ្លូវខេត្ត




### ផ្លូវជនបទ

